**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តក្រចេះ**

# របាយការណ៍សង្ខេប
## ស្តីពី
## " វឌ្ឍនភាព និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តក្រចេះ "
## ក្នុងសន្និសីទសារព័ត៌មាននៅទីស្តីការគណៈរដ្ឋមន្ត្រី

ឯកឧត្តម **ម៉ែន លីណាត** អភិបាលរងខេត្តក្រចេះ

(ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១)

- សូមក្រាបថ្វាយបង្គំ **សម្តេចព្រះសង្ឃរាជទាំងពីរគណៈ** ជាទីគោរពសក្ការៈ!
- សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុន្នី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល **ជាទីគោរព !**
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលមានវត្តមាននៅក្នុងអង្គសន្និសីទសារព័ត៌មាននាពេលនេះ **ជាទីមេត្រី!**
- បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ **ជាទីគោរពស្រលាញ់រាប់អាន!**

ថ្ងៃនេះ ជំនួសមុខរដ្ឋបាលខេត្តក្រចេះ ខ្ញុំពិតជាមានក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំសន្និសីទសារព័ត៌មានស្តីពី **"វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តក្រចេះ"** និងសូមថ្លែងអំណរគុណដល់បងប្អូន ក្មួយៗ អ្នកសារព័ត៌មាន ដែលមានវត្តមាននៅទីនេះ ក៏ដូចជាបងប្អូនប្រជាពលរដ្ឋ

ដែលកំពុងតាមដានសន្និសីទសារព័ត៌មាននាឱកាសនេះផងដែរ ។

ខេត្តក្រចេះ គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត ទាំង ២៥ នៃព្រះរាជាណាចក្រកម្ពុជា។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនាំសន្តិភាពជូនប្រទេស និងប្រជាជនកម្ពុជា **"សូមអរគុណសន្តិភាព"** ដែលធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព ស្ថេរភាពនយោបាយ សុវត្ថិភាព សន្តិសុខ និងការអភិវឌ្ឍលើគ្រប់វិស័យ ។ តាមរយៈការចង្អុលបង្ហាញដោយផ្ទាល់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងមានគោលនយោបាយយុទ្ធសាស្ត្រចតុកោណទាំង៤ ដំណាក់កាល ផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលបានអនុម័តដោយក្រុមប្រឹក្សាខេត្ត គឺជាត្រីវិស័យសម្រាប់ឱ្យរដ្ឋបាលខេត្តក្រចេះ សម្រេចបាននូវសមិទ្ធផលជាច្រើនរួមមាន៖ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ ការកែលម្អរសោភ័ណភាពបរិស្ថាន សន្តិសុខសាធារណៈ និងការផ្តល់សេវាសាធារណៈជាដើម ។ ហើយក្នុងសន្និសីទសារព័ត៌មាននាពេលនេះ ជាឱកាសដ៏ល្អមួយដែលរដ្ឋបាលខេត្តក្រចេះ បានបង្ហាញអំពីវឌ្ឍនភាព និងទិសដៅការងាររបស់ខ្លួនដល់សាធារណៈជនគ្រប់មជ្ឈដ្ឋានទាំងអស់បានជ្រាប និងយល់កាន់តែច្បាស់បន្ថែមទៀត ។ ខ្ញុំសូមអនុញ្ញាតលើកបង្ហាញដោយសង្ខេបអំពីស្ថានភាពទូទៅ និងវឌ្ឍនភាពរួមសំខាន់ៗមានដូចខាងក្រោម ៖

## I. ស្ថានភាពទូទៅ៖

ខេត្តក្រចេះ ជាខេត្តមួយស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា មានចម្ងាយពីរាជធានីភ្នំពេញ **៣៤០ គ.ម** តាមផ្លូវជាតិលេខ៧ កាត់តាមស្រុកស្នួល ចម្ងាយ **២៥០គម** តាមផ្លូវជាតិលេខ ៧៣ កាត់តាមស្រុកឆ្លូង និងចម្ងាយ **២២០ គ.ម** តាមផ្លូវទឹកទន្លេមេគង្គ។ ព្រំប្រទល់ខាងត្បូងជាប់ខេត្តត្បូងឃ្មុំ ខាងជើងជាប់ខេត្តស្ទឹងត្រែង ខាងកើតជាប់ខេត្តមណ្ឌលគីរី និងប្រទេសវៀតណាម ខាងលិចជាប់ខេត្តកំពង់ចាម និងខេត្តកំពង់ធំ ។ ចែកចេញជា**១ក្រុង** និង**៥ស្រុក** ដែលមាន **៥សង្កាត់** និង**៤២ឃុំ** និងមាន **២៥៨ភូមិ** ដែលមានផ្ទៃដីធម្មជាតិសរុប **១១.០៩៤ គម**$^{២}$ ចែកចេញជាពីរតំបន់សំខាន់ៗ ៖ប៉ែកខាងជើង និងខាងកើតជាតំបន់ខ្ពង់រាប មានព្រៃឈើច្រើន មានស្មៅច្រើនប្រភេទ និងមានប្រភេទដីក្រហម អំណោយផលដល់ការចិញ្ចឹមសត្វគោ ក្របី និងការដាំដំណាំកសិ-ឧស្សាហកម្ម ដូចជាកៅស៊ូ ម្រេច ស្វាយចន្ទី..។ល។ រីឯប៉ែកខាងត្បូង និងខាងលិចជាតំបន់ទំនាប និងតំបន់ដីសើមតាមដងទន្លេមេគង្គ សំបូរទៅដោយបឹង ព្រែក អូរ ដីល្បាប់ មានដីជាតិ អំណោយផលដល់ការចិញ្ចឹមត្រី និងដាំដំណាំស្បៀងដូចជាស្រូវ ពោត សណ្តែក ល្ង.. ។ល។ ពិសេសទៅទៀតតំបន់ដីសើមសំបូរទៅដោយជម្រកមច្ឆាជាតិ ចម្រុះពង និងបន្តពូជ និងមានសត្វផ្សោតទន្លេមេគង្គដែលជាសត្វមច្ឆាជាតិ ដ៏កម្រ និងកំពុងទាក់ទាញភ្ញៀវទេសចរណ៍ ជាតិ -អន្តរជាតិមកទស្សនាកំសាន្តកាន់តែច្រើនឡើងជារៀងរាល់ឆ្នាំ ។ មានប្រជាជនសរុប **៤១៧.៣២១ នាក់** ស្មើនឹង **៩៤.០៨០ គ្រួសារ** ក្នុងនោះស្រី**២១០.៨៣៧ នាក់** មានដងស៊ីតេប្រជាជន **៣៧នាក់** ក្នុង១ គម$^{២}$ ។ មានជនជាតិដើមភាគតិចចំនួន៧គឺ៖ ភ្នង កួយ ស្ទៀង ក្រោល មិល ថ្មូន និងជនជាតិខោល ។ ៨១% ជាកសិករពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម ដែលជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ខ្លួន។

ក្រៅពីមុខរបរកសិកម្ម មានប្រជាពលរដ្ឋប្រកបមុខរបរសិប្បកម្មប្រមាណ ០,៣% មុខរបរសេវាកម្មប្រមាណ ១៨,៦%។ សេដ្ឋកិច្ចខេត្តក្រចេះ មានប្រមាណ ៥៤៧ លានដុល្លារ (ស្មើ ២,៤% នៃសេដ្ឋកិច្ចជាតិ) ប្រៀបធៀបឆ្នាំ២០១៨ មានកំណើន ៦,៣% ក្នុងនោះប្រជាជនមានចំណូលសម្រាប់មនុស្សម្នាក់ (GDP) ឆ្នាំ២០១៩ ចំនួន **១.៣៨១ដុល្លារ** កើនជាងឆ្នាំ២០១៨ ដែលប្រជាជនមានចំណូលតែ ១.២៨៤ដុល្លារ កើន ៩៧ដុល្លារ។

## II. **វឌ្ឍនភាពការងារ និងសមិទ្ធផលឆ្នាំ ២០២០ ៖**

### ១. ***ការពង្រីកវិស័យកសិកម្ម និងវិស័យពាណិជ្ជកម្ម***

#### ***ក- សមិទ្ធផលនៃការដាំដុះ***

ខេត្តក្រចេះមានផ្ទៃដីកសិកម្ម ដំណាំស្រូវប្រាំង និងស្រូវវស្សា ក្នុងឆ្នាំ២០២០ អនុវត្តបានចំនួន **៥៤.៥៧២ហិកតា** ស្មើនឹង**១១៦%** នៃផែនការ **៤៧.០០០ហិកតា** ។ ទទួលបានផលស្រូវសរុប **១៧៥.៨៨៦តោន** បើប្រៀបធៀបឆ្នាំ២០១៩ មានបរិមាណខ្ពស់ជាងចំនួន **២៤.៧៥៦តោន** ផ្គត់ផ្គង់តម្រូវការគ្រប់គ្រាន់ក្នុងខេត្ត និងសល់ស្រូវនាំចេញជារៀងរាល់ឆ្នាំថែមទៀត។ ខេត្តមានក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ច **៤៩ក្រុមហ៊ុន** លើផ្ទៃដី**១៩៨.៩៧០ហិកតា** ដាំដំណាំកៅស៊ូបាន **៨៣.១៨៤,៥៣ ហិកតា** ចេកអំបូងលឿង **៣.០៦៦ហិកតា** ទទួលបានទិន្នផល **២៥.៨០០**តោន និងដំណាំផ្សេងៗមានៈ ដំឡូងមី ម៉ៃសាក់ កាស្យា និងអំពៅជាដើម។ ក្រៅពីនោះមានដំណាំជាលក្ខណៈគ្រួសារសម្រេចបានកៅស៊ូ **២២.០៧៦ហិកតា** ស្វាយចន្ទី**៤៣.៩០០ហិកតា** ម្រេច **៧៩៨ ហិកតា** ដំឡូងមី **៦៦.៥០៩ហិកតា** និងដំណាំរួមផ្សំជាច្រើនពាន់ហិកតាទៀត ជាមួយនឹងការពង្រីកបន្ថែមការចិញ្ចឹមសត្វ គោ ក្របី ជ្រូក មាន់ ទា និងបន្លែ ។ល។ សំដៅធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកាន់តែមានភាពប្រសើរឡើងជាលំដាប់ ។

បច្ចុប្បន្នក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋមានចំនួន **៣២ ក្រុមហ៊ុន** មានផ្ទៃដីសរុបចំនួន**១៤១.៨៩១,៥០ហ.ត** ។

ខេត្តមានតំបន់សេដ្ឋកិច្ចពិសេស**០១កន្លែង** លើផ្ទៃដី **៨១៨ហត** ស្ថិតនៅក្នុងស្រុកស្នួល បានវិនិយោគដោយក្រុមហ៊ុន យូប៊ីអីស្នួល មកពីសាធារណៈរដ្ឋប្រជាមានិតចិន ដោយទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលរួច បច្ចុប្បន្នកំពុងដំណើរការសាងសង់រោងចក្រ សហគ្រាស ចំនួន **០៩ទីតាំង** និងគម្រោងអភិវឌ្ឍន៍បន្តបន្ទាប់ទៀត ។ ទន្ទឹមនេះក៏មានក្រុមហ៊ុនកំពុងវិនិយោគសាងសង់រោងចក្រកែច្នៃផលិតផលកសិកម្មចំនួន **០៣កន្លែង** រួមមានៈ រោងចក្រកែច្នៃគ្រឿងសង្ហារឹម **០១កន្លែង** និងរោងចក្រផលិតម្សៅដំឡូងមី **០១កន្លែង** ។

ខេត្តមានផែស្ងួត០១កន្លែង ស្ថិតក្នុងស្រុកស្នួល ខេត្តក្រចេះ ដែលជាកន្លែងដ៏សំខាន់សម្រាប់ចរាចរណ៍ទំនិញ ចេញចូល ។

ក្នុងឆ្នាំ២០២០ ទឹកទន្លេមេគង្គឡើងដល់កម្រិតអតិបរិមាកម្ពស់ ១៩,០៥ម៉ែត្រ ធ្វើឲ្យប៉ះពាល់ដំណាំស្រូវចំនួន **២.២៧៥,២៧ហិកតា** ក្នុងនោះខូចខាតទាំងស្រុងចំនួន **១.៧០៤,៥៧ហិកតា** និងដំណាំរួមផ្សំ ៩៤,៧៥ហិកតា នៅក្នុងស្រុកចំនួន ៣ស្រុក គឺស្រុកព្រែកប្រសព្វ ស្រុកចិត្របុរី ស្រុកឆ្លូង

និងក្រុងក្រចេះ មាន១៨ឃុំ ០៣សង្កាត់ លើ៨០ភូមិ ស្មើនិង២.៣៧២គ្រួសារ។ ក្នុងការឆ្លើយតបអន្តរាគមន៍ **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** បានយកចិត្តទុកដាក់ខ្ពស់ចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តក្រចេះ ផ្តល់ស្រូវជូនប្រជាពលរដ្ឋរងការខូចខាតដោយទឹកទន្លេមេគង្គចំនួន **២៣៧,២តោន** សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋ **២.៣៧២គ្រួសារ** រួមទាំងថវិកាមួយចំនួន។

**ខ- ការជម្រុញវិស័យពាណិជ្ជកម្មក្នុងស្រុក**

ដើម្បីបង្កើនសេដ្ឋកិច្ចក្នុងខេត្ត ក៏ដូចជាការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋ រដ្ឋបាលខេត្តបានពង្រីកវិសាលភាពការដាំដុះ និងចូលរួមលើការគាំទ្រដល់ម្ចាស់អាជីវកម្មខ្នាតតូច និងមធ្យម ដើម្បីស្វែងរកទីផ្សារ ទាំងក្នុងស្រុក និងក្រៅស្រុក ដោយមានការលើកទឹកចិត្ត និងជម្រុញផលិតផលរបស់ប្រជាពលរដ្ឋតាមរយៈការរៀបចំតាំងពិព័រណ៌ផ្សព្វផ្សាយផលិតផលថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ជាច្រើនលើកក្នុងន័យអភិវឌ្ឍន៍ ផលិតផល និងសហគ្រាស ឲ្យមានការរីកចម្រើន និងមានការគាំទ្រពីសំណាក់អ្នកប្រើប្រាស់ដោយមានការខិតខំជ្រោមជ្រែងពីរដ្ឋបាលគ្រប់ថ្នាក់ ក៏ដូចជាការជម្រុញចលនា ភូមិមួយផលិតផលមួយ ដែលយើងមានសមាគម និងសហគមន៏ មានផលិតផលល្បីក្នុងទីផ្សាររួមមាន ៖ សមាគមក្រូចថ្លុងកោះទ្រង់ក្រចេះ ស្ថិតក្នុងសង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ ត្រូវបានក្រសួងពាណិជ្ជកម្មសហការណ៍ជាមួយអង្គការពាក់ព័ន្ធរៀបចំចុះបញ្ជីទំនិញសម្គាល់ភូមិសាស្ត្រ និងត្រូវបានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនៅខែមិថុនា ឆ្នាំ២០១៨ ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។ មានប្រជាកសិករចំនួន**៣៥០គ្រួសារ** ដាំក្រូចថ្លុងលើផ្ទៃដី ៣០ហិកតា មានដើមក្រូចប្រមាណ **៤.០០០ដើម** ទទួលផលក្នុង១ឆ្នាំ **៤០០.០០០ផ្លែ** តម្លៃលក់ **១០.០០០រៀល** ទៅ**១៤.០០០រៀល**ក្នុង១ផ្លែ បាននឹងកំពុងពង្រីកការដាំដុះបន្ថែមទៀតសម្រាប់ចែកចាយទូទាំងរាជធានី ខេត្ត និងសមាគមក្រឡានថ្មគ្រែ ស្ថិតនៅឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ផលិតបានចំនួន **១,៥តោន** ក្នុង១ថ្ងៃ តម្លៃពី៧.០០០រៀល ទៅ១០.០០០រៀល ក្នុង១គីឡូក្រាម ត្រូវបានចែកចាយទូទាំងរាជធានី ខេត្ត ។

**២. ការការពារធនធានធម្មជាតិ**

ខេត្តក្រចេះ មានតំបន់ការពារធនធានធម្មជាតិ **០៦កន្លែង** លើផ្ទៃដីសរុប **៤០៤.០៥៩ហិកតា** ស្ថិតក្នុងភូមិសាស្ត្រស្រុកស្នួល ស្រុកសំបូរ និងស្រុកព្រែកប្រសព្វ រួមមាន៖ ដែនជម្រកសត្វព្រៃ ព្រៃឡង់មានផ្ទៃដី **១០៤.១១៥ហិកតា** ដែនជម្រកសត្វព្រៃកែវសីមាមានផ្ទៃដី **៥៩.៣០១ហិកតា** ដែនជម្រកសត្វព្រៃសំបូរមានផ្ទៃដី **៥០.០៩៣ហិកតា** ដែនជម្រកសត្វព្រៃព្រែកប្រសព្វមានផ្ទៃដី **១២.៧៧០ហិកតា** តំបន់ប្រើប្រាស់ច្រើនយ៉ាងសសរស្តម្ភសត្វគោមានផ្ទៃដី **៨៣៥ហិកតា** របៀងអភិរក្សជីវចម្រុះមានផ្ទៃដី **១៧៧.៧៨០ហិកតា** និងមានស្នាក់ការដែនជម្រកសត្វព្រៃ **០៩កន្លែង** ។ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកម្លាំងសមត្ថកិច្ច និងផ្នែកជំនាញ បានចុះល្បាត និងធ្វើការអប់រំ ណែនាំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋជាប់ជាប្រចាំ ក្នុងគោលដៅថែរក្សា ការពារ និងអភិរក្សដោយទទួលបានលទ្ធផលល្អប្រសើរ។

### ៣. ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### ក- ការកសាងផ្លូវគមនាគមន៍

វិស័យហេដ្ឋារចនាសម្ព័ន្ធ ដោយការវិនិយោគសាធារណៈពីរាជរដ្ឋាភិបាលក្នុងខេត្តក្រចេះបាននឹងកំពុងបន្តកសាង ពង្រីក ជួសជុលផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវលំជនបទ រួមទាំងស្ពានថ្មធំៗ ដោយជានាបាននូវការធ្វើដំណើរកាន់តែមានភាពងាយស្រួលទៅគ្រប់បណ្តាក្រុង ស្រុក ឃុំ សង្កាត់ និងភូមិ ហើយប្រទាក់ក្រឡាគ្នាដល់ជនបទដាច់ស្រយាល បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ និងដឹកជញ្ជូនផលិតផលមកកាន់ទីផ្សារបានយ៉ាងល្អប្រសើរ ។

ខេត្តមានហេដ្ឋារចនាសម្ព័ន្ធក្នុងខេត្តសរុបប្រវែង **៩៨៨,៣៩ គីឡូម៉ែត្រ** ក្នុងនោះផ្លូវកម្រាលកៅស៊ូប្រវែង **៣៨៣,៧៦ គីឡូម៉ែត្រ** ក្រួសក្រហមប្រវែង**៥៩៦,១០គីឡូម៉ែត្រ** ផ្លូវក្នុងក្រុងក្រចេះ (កៅស៊ូ បេតុង) ប្រវែង **៨,៥២ គីឡូម៉ែត្រ** ស្ពានចំនួន ១០៩ កន្លែង ស្មើនឹង**៤.២៥១ម៉ែត្រ** លូ **៣៧៤ កន្លែង** ស្មើនឹង**១៧.២៦៨ម៉ែត្រ** នឹងដាឡូចំនួន**៧៨ កន្លែង** ស្មើនឹង **១.០៩៨ ម៉ែត្រ** ។

ក្នុងឆ្នាំ២០២០នេះ សម្រេចបានការងារ សាងសង់ និងជួសជុលស្ពាន ថ្នល់ ដូចតទៅ៖

-ផ្លូវខេត្តលេខ ៣៧៧,៣៧៧B ,ផ្លូវជាតិលេខ៣៧ និងស្ពានអូរពួក២ សម្រេចបាន១០០%។

-ផ្លូវជាតិលេខ៧៦ សម្រេចបាន ៩៨%,ស្រោចកៅស៊ូ២ជាន់ លើកំណាត់ផ្លូវជាត់លេខ៧៦ បាន៩៦% ,ផ្លូវខេត្តលេខ២៧៩ បាន៨៥% ,និងផ្លូវខេត្តលេខ ៣៧១ បាន៨៣%។

-ថែទាំប្រចាំផ្លូវខេត្ត និងផ្លូវជាតិ សរុបប្រវែង៨១០គីឡូម៉ែត្រ សម្រេចបាន១០០%។

-ស្ថាបនាស្ពានបេតុងស្ពាន**០៥កន្លែង** លើកំណាត់ផ្លូវជាតិលេខ៧៣ ប្រវែង**៤៦០ម៉ែត្រ** ជាជំនួយឥតសំណងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) និងស្ពានអណ្តែងដូន ០១កន្លែង លើកំណាត់ផ្លូវខេត្តលេខ ៣៧៧ ក្នុងក្រុងក្រចេះ ប្រវែង**៣៦ម៉ែត្រ** ជាអំណោយរបស់ខេត្តប៊ិញយឿង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម សម្រេចបាន១០០ % ។

ខេត្តក្រចេះមានច្រកទ្វារព្រំដែន ០១ កន្លែង ជាមួយប្រទេសវៀតណាម ច្រកទ្វារព្រំដែនអន្តរជាតិ ០១ កន្លែង និងច្រកទ្វារព្រំដែនទ្វេរភាគី០២កន្លែង បម្រើដល់ការទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ជាអន្តរជាតិ និងទ្វេភាគីកាន់តែល្អប្រសើរឡើង ។

### ខ-ការកសាងប្រព័ន្ធធារាសាស្ត្រដើម្បីគាំទ្រដល់វិស័យកសិកម្ម

រាជរដ្ឋាភិបាល តាមរយៈក្រសួងធនធានទឹក និងឧតុនិយម ស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធី៣ឆ្នាំរំកិលខេត្ត គិតចាប់ពីឆ្នាំ១៩៩៩ ដល់ដំណាច់ឆ្នាំ២០២០ គឺសំដៅបង្កើន និងពង្រីកប្រព័ន្ធធារាសាស្ត្រ សហគមន៍កសិករប្រើប្រាស់ទឹក បង្កើនបណ្តាញផ្សព្វផ្សាយការងារឧតុនិយម និងជលសាស្ត្រដល់ភូមិ ឃុំ គោលដៅងាយរងគ្រោះ និងការបង្កើនប្រភពទឹក ការគ្រប់គ្រងទឹកបានល្អ សម្រាប់ស្រោចស្រពដំណាំស្រូវ និងកាត់បន្ថយភាពរងគ្រោះដោយបាតុភូតធម្មជាតិ ។ ក្នុងន័យនេះ មន្ទីរធនធានទឹក និងឧតុនិយម និងរដ្ឋបាលខេត្ត បានជួសជុលស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រ **៧២ប្រព័ន្ធ** ប្រព័ន្ធស្រោចស្រប **១៨១ប្រព័ន្ធ** ដោយគិតជារួមទំនប់ប្រវែង **៧៣.៤៨៥ម៉ែត្រ**

ប្រឡាយមេប្រវែង **១៣៥.៧៣២ម៉ែត្រ** ប្រឡាយរងប្រវែង **៦១.១៣៦ម៉ែត្រ** សំណង់បង្ហៀរ **៤៧កន្លែង** ទ្វារទឹក **៧៨កន្លែង** និងលូ **៣៤៥កន្លែង** ។ ស្រោចស្របផ្ទៃដីទូទាំងខេត្តបាន **២៣.៩៧៦ហិកតា** ស្មើនឹង **៥១%** នៃផែនការ **៤៧.០០០ ហិកតា** ដោយគិតទាំងស្រូវប្រាំង និងស្រូវវស្សា ។ សហគមន៍កសិករប្រើប្រាស់ទឹក **៦៧សហគមន៍** ស្ថានីយ៍ជលសាស្ត្រ **០២កន្លែង** និងអាងតម្រងទឹកភ្លៀង **០៨ស្ថានីយ៍**។ ខេត្តបានសាងសង់ប្រាំងទន្លេចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២០ បានប្រវែង **២.៥៣៦ម៉ែត្រ** ។

### ៤. វិស័យធនធានរ៉ែ និងថាមពល

#### ក-ការងាររ៉ែ

ដោយខេត្តក្រចេះ មានសក្តានុពលលើវិស័យធនធានធម្មជាតិ រ៉ែ ថ្មក្រានីត នៅក្នុងភូមិសាស្ត្រស្រុកស្នួល ស្រុកសំបូរ ដែលគៀករបានអ្នកវិនិយោគលើវិស័យនេះ ។ បច្ចុប្បន្នខេត្ត មានក្រុមហ៊ុន/អាជីករមានអាជ្ញាបណ្ណសិក្សាស្រាវជ្រាវ និងធ្វើអាជីវកម្មធនធានរ៉ែ **៤០ក្រុមហ៊ុន** ស្មើនឹង **៤៦អាជ្ញាបណ្ណ** ។ ក្នុងនោះអាជ្ញាបណ្ណសិក្សាស្រាវជ្រាវរ៉ែលោហៈ **០៦ក្រុមហ៊ុន** ស្មើនឹង ០៧អាជ្ញាបណ្ណ បច្ចុប្បន្នបាននឹងកំពុងធ្វើការសិក្សាស្រាវជ្រាវតាមលក្ខខណ្ឌអាជ្ញាបណ្ណរបស់ក្រសួងរ៉ែ និងថាមពល អាជ្ញាបណ្ណឧស្សាហកម្ម-អាជីវកម្មធនធានរ៉ែមាស ០១ក្រុមហ៊ុន ស្មើនឹង០១អាជ្ញាបណ្ណ ,អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម ១៧ ក្រុមហ៊ុន ១៩ អាជ្ញាបណ្ណ និងអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ **១៦អាជីករ** ស្មើនឹង **១៩អាជ្ញាបណ្ណ** ។

#### ខ-ការងារថាមពល

បច្ចុប្បន្នវិស័យថាពលមានការអភិវឌ្ឍយ៉ាងខ្លាំងនៅទូទាំងប្រទេស។ ដោយឡែកខេត្តក្រចេះ អាជ្ញាធរអគ្គិសនីកម្ពុជា បានចេញអាជ្ញាបណ្ណឱ្យអ្នកចែកចាយអគ្គិសនី ០៩ អាជ្ញាបណ្ណ រួមមាន៖ អគ្គិសនីក្រចេះ "EDC" ០១ អាជ្ញាបណ្ណ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គិសនីកម្ពុជា ដែលមានប្រភពថាមពលអគ្គិសនីប្រើប្រាស់ពីប្រទេសវៀតណាម និងអគ្គិសនីឯកជនមាន **០៨អាជ្ញាបណ្ណ** ត្រូវបានគ្របដណ្តប់លើភូមិចំនួន **២១០ភូមិ** ស្មើនឹង ៨១,៤០% នៃភូមិសរុបចំនួន **២៥៨ភូមិ**នៅទូទាំងខេត្ត ។ មានបរិមាណអគ្គិសនីសរុបទូទាំងខេត្ត **១៥៨.៦៤២.៥៩៥គីឡូវ៉ាត់ម៉ោង** បើធៀបឆ្នាំ២០១៨ មាន **១១៤.១៣២.៣៥៧គីឡូវ៉ាត់ម៉ោង** កើនឡើង **៤៤.៥១០.២៣៨គីឡូវ៉ាត់ម៉ោង** ស្មើនឹង ២៨,០៧% ។

#### គ-ការងារទឹកស្អាត

ខេត្តមានអាជីវកម្មទឹកស្អាតឯកជនសរុប ១៦ មូលដ្ឋានដែលគ្របដណ្តប់០១ក្រុង ស្រុក០៥ ស្មើនឹង ២៥ឃុំ ០៤សង្កាត់ និង១១៧ភូមិ ។ ប្រជាពលរដ្ឋទទួលសេវាទឹកស្អាតចំនួន **១០៣.៤០១នាក់** ស្មើ **២២.៩៧៨គ្រួសារ** បរិមាណផលិតទឹកសរុប **៤.០៨១.៨៤១ម៉ែត្រគីប** បរិមាណចែកចាយសរុប **៣.៤៣៧.៦១៧ម៉ែត្រគីប** និងមានបណ្តាញចែកចាយប្រវែង **៥២៨គីឡូម៉ែត្រ** ។

### ៥. វិស័យទេសចរណ៍

វិស័យទេសចរណ៍ ជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗរបស់ខេត្ត មានសត្វផ្សោតទន្លេមេគង្គ មានសំណង់អគារវ័យចំណាស់សល់ពីសម័យអាណានិគមនិយមបារាំង និងជាដែនដីដែលពោរពេញដោយប្រវត្តិសាស្ត្រយូរលង់ ។ ខេត្តបាននឹងកំពុងយកចិត្តទុកដាក់ជម្រុញការ

អភិវឌ្ឍតំបន់រមណីយដ្ឋានទេសចរណ៍ទាំង**១៨កន្លែង** ក្នុងនោះរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ **០៥កន្លែង** រមណីយដ្ឋានធម្មជាតិ **១២ កន្លែង** និងរមណីយដ្ឋានវប្បធម៌ធម្មជាតិ **០១កន្លែង** សហគមន៍អេកូទេសចរណ៍ដែលមានការទាក់ទាញខ្លាំងចំនួន ០៥កន្លែង មានដូចជា ៖ សហគមន៍អេកូទេសចរណ៍កោះទ្រង់ សហគមន៍អេកូទេសចរណ៍កោះផ្តៅ សហគមន៍អេកូទេសចរណ៍កោះសាមសិប សហគមន៍អេកូទេសចរណ៍កោះព្រហ្មចារីយ៍ជ្រោយបន្ទាយទើបបង្កើតថ្មី ពិសេសការអភិរក្សអភិវឌ្ឍន៍តំបន់ទេសចរណ៍សត្វផ្សោតទន្លេមេគង្គ ដែលបច្ចុប្បន្នមានសត្វផ្សោតរស់នៅប្រមាណ**៨០ ក្បាល** កំពុងស្រូបយកភ្ញៀវទេសចរជាតិ-អន្តរជាតិមកទស្សនា និងកំសាន្ត ។ ជាក់ស្តែងក្នុងឆ្នាំ២០២០ ខេត្តមានភ្ញៀវ **១៧៥.១៨៣ នាក់** ក្នុងនោះភ្ញៀវអន្តរជាតិ **៨.៤៣៣នាក់** និងភ្ញៀវជាតិ **១៦៦.៧៥០នាក់** ប្រៀបធៀបឆ្នាំ២០១៩ មានចំនួន **៣៧៣.៦៩៦នាក់** ថយចុះចំនួន **១៩៥.៥១៣ នាក់** ស្មើនឹង **៥៣,១២%** ។

***អាជីវកម្ម សេវាកម្មទេសចរណ៍ ឆ្នាំ២០២០ មាន៖**

- សណ្ឋាគារ ១៥កន្លែង មាន ៦២១បន្ទប់
- ផ្ទះសំណាក់ ៤៨កន្លែង មាន ៤៥០បន្ទប់
- ភោជនីយដ្ឋាន-អាហារដ្ឋាន ៥៨កន្លែង ស្មើនឹង៤៣៩តុ
- សេវាកម្សាន្ត ៣០កន្លែង

### ៦. វិស័យអភិវឌ្ឍន៍ជនបទ

**១.វិស័យផ្លូវជនបទ៖** សម្រេចបានសមិទ្ធផលដូចខាងក្រោម៖ ផ្លូវថែទាំប្រចាំបានចំនួន**៦ខ្សែ** ប្រវែង**១០៧ គីឡូម៉ែត្រ**, ផ្លូវថែទាំលក្ខណៈខួបបានចំនួន៧ខ្សែ ប្រវែង**៤៩គីឡូម៉ែត្រ**, ផ្លូវជួសជុលបន្ទាន់បានចំនួន១ខ្សែ ប្រវែង**៣,៥គីឡូម៉ែត្រ**, ជួសជុលស្ពានឈើបានចំនួន៣កន្លែង ប្រវែងសរុប**៥៤ម៉ែត្រ**, ជួសជុលស្ពានបេតុងបានចំនួន១កន្លែង **ប្រវែង៦ម៉ែត្រ** និងបានសង់រោងទីទួលសុវត្ថិភាពចំនួន**១កន្លែង** ផងដែរ។ បន្ទាប់ពីការងារនេះ គ្រោងនឹងធ្វើការកែប្រែពីផ្លូវដីជនបទ មកជាផ្លូវក្រាលកៅស៊ូ ជនបទប្រភេទ DBST ចំនួន៤ខ្សែ ប្រវែង **៨៣គីឡូម៉ែត្រ** នៅពេលឆាប់ៗខាងមុខក្នុងឆ្នាំ២០២០នេះផងដែរ។

**២.វិស័យផ្គត់ផ្គង់ទឹកជនបទ៖** បានសាងសង់អណ្តូងថ្មីបាន ចំនួន**២០អណ្តូង** ជួសជុលអណ្តូងស្ទះបានចំនួន **២៥៧អណ្តូង** និងឆ្នាំ២០២០នេះ មន្ទីរបានបន្តសាងសង់អណ្តូងថ្មីចំនួន**២១អណ្តូង** ជួសជុលអណ្តូងស្ទះខូចចំនួន**៣៥អណ្តូង** អាងត្រង់ទឹកភ្លៀងចំណុះ**៣៥.០០០លីត្រ** និងស្តារស្រះសហគមន៍ចំនួន**២កន្លែង**។ រហូតមកពេលនេះ អត្រាគ្របដណ្តប់ផ្នែកទឹកស្អាតដែលមានការកែលម្អ មាន៧៥% នៃប្រជាជនសរុបក្នុងខេត្ត

**៣.ការលើកកម្ពស់អនាម័យជនបទ៖** បានផ្សព្វផ្សាយ និងជម្រុញការសាងសង់បង្គន់អនាម័យដល់ខ្នងផ្ទះ បានចំនួន **៧៧.៥៣០ខ្នងផ្ទះ** ក្នុងនោះសាងសង់បង្គន់អនាម័យមាន ចំនួន **៤៦.៥០៧បង្គន់** មកទល់នឹងពេលនេះផងដែរ អត្រាគ្របដណ្តប់ផ្នែកអនាម័យទូទាំងខេត្តមានប្រមាណ៦០%។

### ៧.ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

វិស័យដីធ្លី និងសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនយ៉ាងខ្លាំង ដោយឡែកនៅខេត្តក្រចេះទីផ្សារដីធ្លី និងការសាងសង់រីកដុះដាលគ្រប់ទីកន្លែង ។

**ក-ការងារលំនៅឋាន**

-ផ្តល់ដីសម្បទានសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារចូលនិវត្តន៍ **១២២គ្រួសារ**។

-បានផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រខ្វះដីបានចំនួន **៣.១៨៥គ្រួសារ** ស្មើ ៣.១៨៥ឡូតិ៍ ស្មើ៧.៥៥៤ហិកតា ស្ថិតក្នុងឃុំ២ធ្នូ ស្រុកស្នួល ឃុំដំរីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំឆ្លូង ស្រុកឆ្លូងផ្តល់ជូនសម្រាប់មុខសញ្ញាបាក់ច្រាំងទន្លេ ចំនួន ៩៦ឡូតិ៍ដីលំនៅដ្ឋាន ស្មើ៣,៧៧ហិកតា ។ ក្នុងឆ្នាំ២០២០ បានបែងចែកចំនួន ២១គ្រួសារ ស្មើ២១ឡូតិ៍ ។

**ខ-ការងាររដ្ឋបាលដីធ្លី**

-ចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ចំនួន ០៤ក្រុង ស្រុក(ក្រុងក្រចេះ ស្រុកចិត្របុរី ស្រុកព្រែកប្រសព្វ និងស្រុកឆ្លូង) បានចំនួន **៧.១១៣បណ្ណ** ស្មើ ៤.៣១៨គ្រួសារ ស្មើ ២.៨៣៣,៨៩ហិកតា ។

-ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ០២សហគមន៍ ស្ថិតនៅភូមិស្រែឈូក ឃុំរលួសមានជ័យ និងភូមិត្នោត ឃុំស្រែជិះ ស្រុកសំបូរ ។

-ចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំបានចំនួន ៧០បណ្ណ

-ចុះបញ្ជីផ្ទេរកម្មសិទ្ធបាន ៧៤៥ក្បាលដី

-ចុះបញ្ជីប្រាតិភោគ(ដាក់បញ្ចាំ/ហ៊ីប៉ូតែក) ៥៨៤ក្បាលដី។

**គ-ការងារដោះស្រាយទំនាស់ដីធ្លី**

ក្នុងឆ្នាំ២០២០ បានទទួលពាក្យបណ្តឹងសរុប ៩៥ករណី ក្នុងនោះ៤៩ករណីបញ្ជូនមកពីថ្នាក់ជាតិ និង៤៦ករណី ពាក្យបណ្តឹក្នុងខេត្ត សម្រេចបានលទ្ធផលដូចខាងក្រោម ៖

-ក្រុមការងារដំណោះស្រាយវិវាទដីធ្លី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សហការជាមួយរដ្ឋបាលខេត្ត បានដោះស្រាយបញ្ចប់ ៣២ករណី និង ០៨ករណី កំពុងដោះស្រាយ នៅសល់០៩ករណី ។

-សំណុំរឿងនៅថ្នាក់ខេត្តមានចំនួន ៤៦ ដោះស្រាយបញ្ចប់ ៣៥ករណី កំពុងដោះស្រាយ០៧ករណី នៅសល់០៤ករណី។

**ឃ-ការងារសំណង់**

បានចេញលិខិតអនុញ្ញាតសាងសង់បាន ៣៤គម្រោង មានក្រឡាផ្ទៃសំណង់ ២៧.៩៥៣,៦ ម៉ែត្រការ៉េ ដែលមានទុនវិនិយោគប្រមាណ ៨.៥០៥.៩៦០ដុល្លារ។

## III. វិស័យសង្គមកិច្ច៖

### ១. ផ្នែកអប់រំយុវជន និងកីឡា

វិស័យអប់រំ យុវជន និងកីឡា មានការរីកចម្រើនជាបន្តបន្ទាប់គួរឲ្យកត់សម្គាល់ ដែលបច្ចុប្បន្ននេះមាន៖ បុគ្គលិក **៣.២២៧នាក់** ស្រី**១.៨៤៧នាក់** មានអគារសិក្សាសរុប**៧០៩ខ្នង** ស្មើ **២.៦៩២បន្ទប់**

ក្នុងនោះអគារសិក្សាដែលអំណោយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ចំនួន ១០២ខ្នង ស្មើ ៥៩៧បន្ទប់** ។ មានមត្តេយ្យសិក្សា បឋមសិក្សាគ្រប់ភូមិ អនុវិទ្យាល័យគ្រប់ឃុំ សង្កាត់ វិទ្យាល័យគ្រប់ក្រុង ស្រុក ដោយក្រុង ស្រុកមួយចំនួនមានរហូតដល់ ២ ទៅ ៣ កន្លែង ។ សាកលវិទ្យាល័យរដ្ឋមាន ០១កន្លែង សាកលវិទ្យាល័យ និងវិទ្យាស្ថានឯកជនមាន០២ កន្លែង សាលាចំណេះទូទៅឯកជន០១កន្លែង សាលាគរុកោសល្យ ០១កន្លែង មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ០១កន្លែង និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអភិវឌ្ឍន៍ស្ត្រី ០១កន្លែង ។

**២. ផ្នែកសុខាភិបាល**

វិស័យសុខាភិបាលខេត្ត មានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ **០៣កន្លែង** មន្ទីរពេទ្យបង្អែក **០៥កន្លែង** មណ្ឌលសុខភាព **៣៩កន្លែង** និងប៉ុស្តិ៍សុខភាព **១៤កន្លែង** និងបានបើកការដ្ឋានអគារវះកាត់ និងសម្ភព **០១កន្លែង** ដែលកំពុងដំណើរការបម្រើសេវាសុខភាពយ៉ាងល្អប្រសើរជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ពិសេសកំពុងរួមចំណែកការអនុវត្តគោលនយោបាយជាតិគាំពារសង្គម គោលនយោបាយរបបសន្តិសុខសង្គម និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។

-ស្ថានភាពជំងឺកូវីដ-១៩ ខេត្តក្រចេះ គិតត្រឹមថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ បានអប់រំដោយផ្ទាល់ពីវិធីបង្ការជំងឺឆ្លងជូនពលករដែលបានវិលត្រឡប់មកពីក្រៅប្រទេសសរុបចំនួន ៧៩២ នាក់ ស្រី ២៩៤ នាក់ ក្នុងនោះមកពីប្រទេសថៃចំនួន ៤៩១ នាក់ ស្រី ១៩០នាក់ និងប្រទេសផ្សេងៗ ចំនួន ៣០១ នាក់ ស្រី ១០៤នាក់។

-ក្នុងស្មារតីសាមគ្គីជាតិ និងការចែករំលែក ប្រកបដោយសណ្តានចិត្តសប្បុរសធម៌ មន្ត្រីរាជការ មន្ត្រីនគរបាល បានស្ម័គ្រចិត្តបរិច្ចាគប្រាក់បៀវត្សផ្ទាល់ខ្លួនប្រចាំខែ និងថវិកាផ្ទាល់ខ្លួនរបស់ព្រះមន្ត្រីសង្ឃក្នុងខេត្តក្រចេះ ចំនួន **៧២៧នាក់/អង្គ** ដែលមានថវិកាប្រមាណជាង **៣៩៤ លានរៀល** ជូនមូលនិធិប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្នុងការបង្ការ ទប់ស្កាត់ នៃការរីករាលដាលនៃជំងឺនេះ។

-ការរួមចំណែកជាមួយរាជរដ្ឋាភិបាល ដើម្បីទិញវ៉ាក់សាំងការពារជំងឺកូវីដសម្រាប់ចាក់ជូន ១៩-ប្រជាពលរដ្ឋនៅកម្ពុជាដោយឥតគិតថ្លៃ ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការនៃរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរ អង្គភាពជុំវិញខេត្ត កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ អាជីវករ និងប្រជាពលរដ្ឋក្នុងខេត្តក្រចេះ បានស្ម័គ្រចិត្តបរិច្ចាគថវិកាតាមរយៈរដ្ឋបាលខេត្ត ទឹកប្រាក់សរុបប្រមាណ **២២៣ លាន រៀល** និង **២៧៥០ ដុល្លារ** ។

**IV. វិស័យគ្រប់គ្រងរដ្ឋបាល សន្តិសុខ និងសណ្តាប់សាធារណៈ** ៖

សភាពការណ៍សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានរបៀបរៀបរយ មានសុវត្ថិភាព មានការចូលរួមសហការពីសំណាក់បងប្អូនប្រជាពលរដ្ឋនៅគ្រប់មូលដ្ឋាន និងមានស្មារតីទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក ។ គណៈបញ្ជាការឯកភាពខេត្ត បានធ្វើការប្រជុំអប់រំ ផ្សព្វផ្សាយការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងដាក់វិធានការយ៉ាងតឹងរឹង និងម៉ឺងម៉ាត់បំផុត ។ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រួមជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្នុងការ

បំពេញភារកិច្ចការពារសន្តិសុខសង្គមបានល្អប្រសើរ ។ ក្នុងឆ្នាំ២០២០ បង្ក្រាបបទល្មើស **៥៩លើក** ក្នុងនោះបទឧក្រិដ្ឋ **៣៣លើក** និងបទមជ្ឈឹម **២៦លើក** ។ សណ្តាប់ធ្នាប់ចរាចណ៍ និងសណ្តាប់ធ្នាប់សាធារណៈនៅតែជាបញ្ហាប្រឈម ចាំបាច់ត្រូវប្រមូលផ្តុំវិធានការដោះស្រាយឲ្យបានម៉ឺងម៉ាត់បន្ថែមទៀត ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដល់មនុស្ស និងខូចខាតទ្រព្យសម្បត្តិរបស់ប្រជាជន ។

## V. **កិច្ចសហការជាមួយខេត្តជាប់ព្រំដែន** ៖

ខេត្តក្រចេះ បានពង្រឹងកិច្ចសហការជាមួយខេត្តប៊ិញភឿក និងខេត្តប៊ិញយឿង នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីភាពរីកចម្រើន និងការអភិវឌ្ឍ នៃខេត្តទាំងបី ជាពិសេសលើវិស័យសង្គមកិច្ច សុខាភិបាល អប់រំ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងរបៀបរៀបរយ ។ ទន្ទឹមនឹងនេះ រដ្ឋបាលខេត្តក្រចេះ បានអនុវត្តសកម្មភាពមួយចំនួនជាអាទិ៍ ៖

-កិច្ចប្រជុំផ្លាស់ប្តូរយោបល់ បណ្តុះបណ្តាល សម្របសម្រួល ដោះស្រាយបញ្ហា ទស្សនកិច្ច និង ពិធីផ្សេងៗ ។

-កិច្ចសហការរួមគ្នា រវាងកម្ពុជា និងវៀតណាម ដើម្បីគ្រប់គ្រងជំងឺតាមព្រំដែន បង្ក្រាបការជួញដូរគ្រឿងញៀន ។

-ការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីការឆ្លងកាត់ព្រំដែន( ការប្រើប្រាស់ ប័ណ្ណព្រំដែនបានអនុវត្តល្អប្រសើរសម្រាប់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ព្រំដែន នៃប្រទេសទាំងពីរ )។

-ការសម្រួលដល់ការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន និងផ្លាស់ប្តូរទំនិញកសិផលរបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន ។

## VI. **ការពង្រឹងនៃការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋ** ៖

ក្រៅអំពីការខិតខំប្រឹងប្រែងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា ដើម្បីបម្រើដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ។ រដ្ឋបាលខេត្ត បានខិតខំយកចិត្តទុកដាក់អនុវត្តតាមវិធានគតិយុត្តនានាជាធរមានដោយបត់បែនទៅតាមស្ថានភាពការងារ និងតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ ក្នុងការបម្រើសេវាប្រកបដោយគុណភាព គុណធម៌ ដោយទាក់ទាញបាននូវជំនឿទុកចិត្តយ៉ាងមុតមាំរបស់ប្រជាពលរដ្ឋស្ទើរលើគ្រប់សេវា ដូចជាសេវាអប់រំ សេវាសុខាភិបាល សេវាអត្តសញ្ញាណកម្ម ។ បច្ចុប្បន្ននេះ ប្រជាពលរដ្ឋស្ទើរគ្រប់ក្រុមគ្រួសារសុទ្ធតែមានសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។ ក្នុងឆ្នាំ២០២០ បានផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មីជូនប្រជាពលរដ្ឋសរុប **២៤២.៧០៨នាក់** ក្នុងនោះប្រជាពលរដ្ឋអាយុ១៥ឆ្នាំឡើងសរុប **១៤.៣២៦នាក់ ស្រី៦.៨៨៧នាក់ ។** ក្រៅពីសេវាខាងលើ រដ្ឋបាលខេត្ត បានពង្រីកការបម្រើសេវាផ្សេងៗទៀតតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យនានាផងដែរ ។

អង្គភាពច្រកចេញចូលតែមួយខេត្តក្រចេះ ត្រូវបានដាក់ឲ្យដំណើរការផ្តល់សេវាជាបណ្តោះអាសន្ននៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ និងសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០២០ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង

មហាផ្ទៃ ។ ក្នុងរយៈពេល១ឆ្នាំ២០២០ អង្គភាពច្រកចេញចូលតែមួយខេត្ត មានវិស័យ ចំនួន១៤ ផ្តល់សេវាបានចំនួន **៥.៥៤៥សេវា** និងទទួលបានចំណូលសរុបចំនួន **៨៤៩.១៩៣.៨៩២ រៀល**(ប្រាំបីរយសែសិបប្រាំបួនលាន មួយរយកៅសិបបីពាន់ ប្រាំបីរយកៅសិបពីរពាន់រៀលគត់) ។ ដោយឡែកការិយាល័យច្រកចេញចូលតែមួយក្រុងក្រចេះ និងស្រុកផ្សេងៗទៀតបាននឹងកំពុងដាក់ឲ្យដំណើរការ ។ បច្ចុប្បន្ន រដ្ឋបាលក្រុង ស្រុក បានដាក់ដំណើរការក្នុងរចនាសម្ព័ន្ធថ្មីដែលមាន ១២ការិយាល័យ និង ០១ អង្គភាព ហើយតួនាទី ភារកិច្ច ក៏មានវិសាលភាពធំជាងមុនតាមការធ្វើប្រតិភូកម្មអំណាចពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ កម្មវិធីកំណែទម្រង់ស៊ីជម្រៅនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ បានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ និងមានឆន្ទៈមោះមុត ពុះពាររាល់ការលំបាកគ្រប់បែបយ៉ាង ដោយឈរលើស្មារតីសាមគ្គី សហការ រក្សាបានសន្តិសុខ សុវត្ថិភាព ស្ថិរភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយបានល្អប្រសើរ សម្រេចបានលទ្ធផលគួរឲ្យកត់សម្គាល់ ដែលប្រជាពលរដ្ឋមានការគាំទ្រ និងអបអរសាទរ ។ ទន្ទឹមនឹងសមិទ្ធផលដែលយើងសម្រេចបាន ក៏នៅមានបញ្ហាមួយចំនួន ដែលនៅមិនទាន់អនុវត្តបានទាំងស្រុងតាមតម្រូវការ និងសំណូមពរប្រជាពលរដ្ឋនៅឡើយ ដែលបានលើកឡើងតាមរយៈការចុះធ្វើវេទិកាសាធារណៈ តាមឃុំ សង្កាត់ទូទាំងខេត្តក្នុង ឆ្នាំ២០២០ នេះ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តក្រចេះ បានចុះធ្វើវេទិកាសាធារណៈ នៅតាមមូលដ្ឋានក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាន **៤១លើក** អ្នកចូលរួម **៥.០២១នាក់** ស្រី **១.១៧៣នាក់** បញ្ហាប្រឈមមានចំនួន **២២៩ករណី** ក្រុមការងារដោះស្រាយបាន **១៣២ ករណី** កំពុងដោះស្រាយ **៨៩ករណី** និងមិនទាន់ដោះស្រាយ **០៨ករណី** ជាបញ្ហាធំលើសពីសមត្ថកិច្ចខេត្តដោះស្រាយ ។

## VII. ទិសដៅការងារអនុវត្តបន្ត ៖

ទន្ទឹមនឹងលទ្ធផលការងារសម្រេចបានខាងលើ និងដើម្បីបន្តភាពរីកចម្រើនបន្តទៀតនោះ រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តដូចតទៅ ៖

- ជំរុញការអនុវត្តគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាលអាណត្តិទី៦
- បន្តកសាង និងពង្រឹងសន្តិសុខ សុវត្ថិភាព ជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការខិតខំលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋានភូមិ ឃុំ សង្កាត់ ទូទាំងខេត្ត។
- បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីគ្រប់សមាសភាពផ្សេងៗទាំងក្នុងវិស័យសាធារណៈ ទាំងវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីកសាងកម្លាំងសរុប ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ។
- ត្រៀមសហការជាមួយក្រុមហ៊ុនវិនិយោគ ដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍គម្រោងនានាក្នុងខេត្ត។
- ត្រៀមរៀបចំ កែលម្អ និងលើកគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់រដ្ឋបាលខេត្ត ។

- បន្តការគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការអនុវត្តមុខងារទៅតាមរចនាសម្ព័ន្ធថ្មី និងមុខងារ ដែលត្រូវបានផ្ទេរពីថ្នាក់ជាតិ។
- បន្តពង្រឹងគុណភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក តាមរយៈអង្គភាព និងការិយាល័យច្រកចេញចូលតែមួយដែលមានស្រាប់ ។
- រៀបចំវេទិកាពិគ្រោះយោបល់ជាសាធារណៈជាមួយប្រជាពលរដ្ឋ ស្វែងយល់ពីសុខទុក្ខ និងតម្រូវការនៅមូលដ្ឋាន ដើម្បីរៀបចំផែនការឆ្លើយតបឲ្យបានទាន់ពេលវេលា។
- បន្តធ្វើការសិក្សាគម្រោងប្តូរទីតាំងលម្អិតសម្រាប់អនុវត្តគម្រោងសាងសង់ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ និងទីលានកប់សំរាមក្រុងក្រចេះ នៃគម្រោងអភិវឌ្ឍន៍ក្រុងរបៀង៤ ។
- បង្កើនការអប់រំ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋលើការទុកដាក់ ការគ្រប់គ្រងសំរាម សំណល់រឹង រាវ ព្រមទាំងត្រៀមរៀបចំទីលាន និងបច្ចេកទេសក្នុងទុកដាក់ និងកែច្នៃសំរាម។
- បន្តការងារដោះស្រាយទំនាស់ដីធ្លី ដែលនៅសេសសល់ និងបន្តចុះបញ្ជីដីរដ្ឋ ។
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីខេត្តជាមិត្តនៃប្រទេសជិតខាង ។
- បន្តរួមរួមទប់ស្កាត់នៃការរីករាលដាលជំងឺកូវីដ-១៩ ដោយបានធ្វើផែនការលម្អិត សម្រាប់ប្រយុទ្ធប្រឆាំងប្រកបដោយភាពជោគជ័យ គឺមានន័យថាខេត្តក្រចេះពុំមានជំងឺកូវីដ-១៩នោះទេ ។

**សូមអរគុណ!**